# មេរៀនទី ១៣៧៖ សាឡូម៉ូនខាកបែរពីព្រះ

១ពង្សាវតារក្សត្រ ១១៖១-១៣

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/CKE12nshf4E

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/INHzXnuiCvw

**គោលបំណង៖** ព្រះទ្រង់ស័ក្តិសមនឹងទទួលបាននូវការថ្វាយបង្គំដ៏ពិតពីយើងរាល់គ្នា។

**ខគម្ពីរចងចាំ៖ ចោទិយកថា ៦៖៥** *“ ត្រូវឲ្យឯងស្រឡាញ់ព្រះយេហូវ៉ា ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ពីកំឡាំងឯង។”*

**ចំរៀង** ( *យូធូបលីង* )៖

១. ក្បាល ស្មា ជង្គង់ ចុងជើង សរសើរព្រះអង្គ https://youtu.be/nh0Ekk87w4s

២. សរសើរព្រះយេស៊ូវ https://youtu.be/uA448Ncse8Q

៣. ចូរប្រយ័ត្ននឹងភ្នែកតូចអ្នក https://youtu.be/leoAGL9usF0

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «តាតាសុំដូង»

សម្ភារៈដែលត្រូវការ៖ គុម្មួយ កៅអីមួយ



១. ជ្រើសកុមារម្នាក់ដើរតួជា តា ហើយកុមារម្នាក់ទៀតដើរតួជាអ្នកសុំដូង

២.ឲ្យកុមារដែលនៅសល់ចែកជាពីរក្រុម។ ក្រុមមួយដើរតួជាឃ្មុំ ក្រុមមួយដើរតួជាដូង។

៣. ក្រុមដូងត្រូវអង្គុយ ជាជួរតោងចង្កេះគ្នាកុមារ ដំបូងគេត្រូវតោងភ្ជាប់ជាមួយជើងតុដើរតួជាដូង។ ក្រុមឃ្មុំ អាចតោងនៅលើដូងណាមួយក៏បាន។

៤. ពេលអ្នកសុំទៅដល់ គេត្រូវនិយាយថា “តាៗ សុំដូងមួយ” តាតបថា“ស្រលាញ់មួយណាបេះមួយ ហ្នឹងចុះ” អ្នកសុំតបថា “អរគុណតា”។

៥. អ្នកសុំក៏ដើរទៅបេះដូងដែលគេចង់បាន។ប្រសិនបើគេបេះចំដូងដែលមានឃ្មុំនោះឃ្មុំនឹងទិចគេ។ ហើយគេនឹងចាញ់ល្បែងនេះ។

៦. ប្រសិនបើអ្នកសុំមិនរើសចំដូងដែលមានឃ្មុំទេនោះគេនឹងឈ្នះ ហើយដើរតួជាឃ្មុំវិញម្តង។

៧. អ្នកដែលជាដូងត្រូវបានគេសុំនោះត្រូវធ្វើជាអ្នក ទៅសុំដូងតាវិញម្តង។

៨.មិនយូរមិនឆាប់កុមារដែលជាអ្នកសុំនឹងត្រូវរើសយកដូងដែលមានឃ្មុំនោះហើយគេនឹងចាញ់ល្បែង នេះ។

៩.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ប្រសិនបើយើងចង់សុំអ្វីពីព្រះ នោះទ្រង់នឹងប្រទានដល់យើងប្រសិនបើរបស់នោះមិនធ្វើឲ្យយើងឈឺចាប់។ ព្រះសមនឹងទទួលបានការថ្វាយបង្គំដ៏ពេញលេញពីយើង ដោយសារទ្រង់ស្រលាញ់យើង ហើយទ្រង់នឹងប្រទាននូវអ្វីដែលយើងត្រូវការ។

## ៤. ការណែនាំមេរៀន

នៅពេលដែលប្អូនប្រាប់ឪពុកម្តាយរបស់ប្អូនថាប្អូនស្រលាញ់គាត់ តើប្អូនស្រលាញ់ពួកគាត់ដោយអស់ពីចិត្តឬមួយយ៉ាងណា? តើប្អូនមានអារម្មណ៍ដូចម្តេច នៅពេលដែលម្តាយរបស់ប្អូនប្រាប់ប្អូនថា គាត់ស្រលាញ់ប្អូនមិនអស់ពីចិត្តរបស់គាត់នោះ? តើការនោះធ្វើឲ្យប្អូនសប្បាយឬក៏ទុក្ខសោក? ព្រះចង់ឲ្យយើងស្រលាញ់ទ្រង់ឲ្យអស់ពីចិត្តរបស់យើង។ ពីព្រោះទ្រង់ស័ក្តិសមនឹងទទួលបាននូវការថ្វាយបង្គំដ៏ពិតពីយើងរាល់គ្នា។ នេះគឺមានន័យថា ទ្រង់សមនឹងទទួលបាននូវសេចក្តីស្រលាញ់ និងការទុកចិត្តពីយើងរាល់គ្នាគ្រប់ពេលនិងជារៀងរាល់ថ្ងៃ។ ថ្ងៃនេះ យើងនឹងរៀនអំពីបុរសម្នាក់ដែលមិនបានថ្វាយបង្គំព្រះឲ្យអស់ពីចិត្តរបស់គាត់នោះទេ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាឡូម៉ូនជាស្តេចរបស់សាសន៍អ៊ីស្រាអែល។ ស្តេចសាឡូម៉ូនគឺស្រឡាញ់និងបម្រើព្រះ។ គាត់បានផ្តល់សេចក្តីស្រឡាញ់ដល់ព្រះគ្រប់ពេលវេលា។ គាត់ស្រឡាញ់ព្រះពេលគាត់នៅជាមួយគ្រួសាររបស់គាត់។ គាត់ស្រឡាញ់ព្រះពេលគាត់នៅជាមួយមិត្តរបស់គាត់។ គាត់ស្រឡាញ់ព្រះ ហើយស្តាប់បង្គាប់ព្រះ ពេលគាត់ព្យាយាមដោះស្រាយបញ្ហាដែលកើតឡើងក្នុងប្រទេសអ៊ីស្រាអែល។ គាត់បានថ្វាយបង្គំព្រះនៅឯព្រះវិហារ។ ដួងចិត្តទាំងអស់របស់សាឡូម៉ូនគឺសម្រាប់ព្រះ។

ប៉ុន្តែបន្ទាប់មកសាឡូម៉ូនមិនស្តាប់បង្គាប់ព្រះ។ គាត់បានរៀបការជាមួយស្ត្រីខ្លះដែលមិនស្រឡាញ់ព្រះ។ ស្ត្រីទាំងនេះគោរពបូជារូបព្រះ ហើយពួកគេមិនចង់ឲ្យសាឡូម៉ូនថ្វាយបង្គំព្រះឡើយ។ ដូច្នេះ ជាជាងស្រឡាញ់ព្រះគ្រប់ពេលនោះ សាឡូម៉ូនបានងាកបែរចេញពីព្រះបន្តិចម្តងៗ ហើយដួងចិត្តដែលស្រលាញ់ព្រះក៏នៅសល់តែបន្តិចប៉ុណ្ណោះ។ ដួងចិត្តដែលនៅសេសសល់គាត់បានប្រគល់ទៅឲ្យស្រីៗទាំងនោះអស់ហើយ។

បន្ទាប់មក គាត់ចាប់ផ្តើមថ្វាយបង្គំរូបព្រះជាមួយនឹងស្ត្រីដែលគាត់បានរៀបការជាមួយនោះ! សាឡូម៉ូនលែងប្រគល់ដួងចិត្តទាំងអស់ថ្វាយដល់ព្រះទៀតហើយ។ ហើយព្រះមិនចង់បាន គ្រាន់តែជាផ្នែកមួយនៃចិត្តយើងទេ។ ព្រះបានមានបន្ទូលប្រាប់សាឡូម៉ូនថា ទ្រង់ខឹងណាស់ ហើយទ្រង់នឹងយករាជបល្ល័ងចេញពី កូនរបស់សាឡូម៉ូន ដូច្នេះគ្រួសាររបស់សាឡូម៉ូននឹងលែងធ្វើជាស្តេចលើដែនដីអ៊ីស្រាអែលទៀតហើយ។

ព្រះសមនឹងទទួលបានដួងចិត្តរបស់យើងទាំងស្រុង។ ទ្រង់ស័ក្តិសមនឹងទទួលបាននូវការថ្វាយបង្គំដ៏ពិតពីយើងរាល់គ្នា ពីព្រោះទ្រង់អស្ចារ្យណាស់។ មានតែព្រះប៉ុណ្ណោះដែលអស្ចារ្យសមនឹងទទួលបានសេចក្តីស្រឡាញ់របស់យើងគ្រប់ពេលវេលា។ ទ្រង់ស្រឡាញ់យើង ហើយយកចិត្តទុកដាក់ចំពោះយើង ហើយទ្រង់បានបង្កើតពិភពលោកទាំងមូលសម្រាប់យើង។ យើងគួរស្រឡាញ់ព្រះ ហើយដើរតាមមាគ៌ារបស់ព្រះអង្គ ពេលយើងនៅផ្ទះ នៅជាមួយមិត្តភ័ក្តិ នៅព្រះវិហារ និងគ្រប់ទីកន្លែងដែលយើងទៅ។ យើងគួរតែស្រឡាញ់ទ្រង់គ្រប់ពេលវេលា។ យើងគួរតែផ្តល់ឲ្យព្រះអង្គនូវដួងចិត្តទាំងអស់របស់យើង។

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាសាឡូម៉ូនងាកបែរចេញពីព្រះ? *(គាត់បានរៀបការជាមួយស្ត្រីខ្លះដែលមិនជឿព្រះ)*

២. តើព្រះបានមានបន្ទូលដូចម្តេចទៅកាន់សាឡូម៉ូន?
*(ទ្រង់ខឹងណាស់ ហើយទ្រង់នឹងយករាជបល្ល័ង ចេញពីកូនរបស់សាឡូម៉ូន)*

៣. តើយើងត្រូវធ្វើដូចម្តេច ដើម្បីបង្ហាញពីសេចក្តីស្រលាញ់របស់យើងដែលមានចំពោះព្រះ?

*(យើងគួរតែផ្តល់ឲ្យព្រះអង្គនូវដួងចិត្តទាំងអស់របស់យើងទៅព្រះ ដោយការអធិស្ឋាន ការថ្វាយបង្គំ និងការដែលចិត្តល្អចំពោះមិត្តភក្តិ ។ល។)*

៤. តើយើងគួរប្រគល់ដួងចិត្តរបស់យើងប៉ុនណាសម្រាប់ព្រះ? *(ដួងចិត្តទាំងមូលរបស់យើង)*

## ៧. ល្បែងកំសាន្ត «ព្រះទ្រង់ស័ក្តិសមនឹងទទួលបាននូវការថ្វាយបង្គំដ៏ពិតពីយើងរាល់គ្នា»



១. ឲ្យកុមារទាំងអស់ឈរនៅចំកណ្តាលថ្នាក់រៀន

២. គ្រូនឹងអានប្រយោគ ហើយនៅពេលដែលសិស្សលឺ "ចន្លោះដែលទំនេរ" គេត្រូវរត់ទៅរកចម្លើយ ដែលត្រឹមត្រូវនោះ។ ប្រសិនបើកុមារគិតថា ចម្លើយទី១ ត្រឹមត្រូវពួកគេត្រូវរត់ទៅខាងស្តាំ ហើយពួកគេត្រូវរត់ទៅខាងឆ្វេងបើគិតថា ចម្លើយទី ២ត្រឹមត្រូវ។

ក. សាឡូម៉ូនងាកបែរចេញពីព្រះដោយសារ........ (**ប្រពន្ធគាត់**/ទ្រព្យសម្បត្តិ)

ខ. ទ្រ*ង់នឹងយក* ........(ទ្រព្យសម្បត្តិ/***រាជបល្ល័ល***)ចេញពីកូនរបស់សាឡូម៉ូន

គ. មានតែ.......(**ព្រះ**/ជីតា) ប៉ុណ្ណោះដែលអស្ចារ្យសមនឹងទទួលបានសេចក្តីស្រឡាញ់របស់យើងគ្រប់ពេលវេលា

ឃ. ទ្រង់ស្រឡាញ់យើងហើយយកចិត្តទុកដាក់ចំពោះយើង ហើយទ្រង់បានបង្កើត............... (**ពិភពលោក**/ផែនដីខ្លះ) ទាំងមូលសម្រាប់យើង។

ង. យើងគួរស្រឡាញ់ព្រះហើយដើរតាមមាគ៌ារបស់ព្រះអង្គ ពេលយើងនៅផ្ទះ នៅជាមួយមិត្តភ័ក្តិ នៅព្រះវិហារ និងគ្រប់......(**គ្រប់ទីកន្លែង**/កន្លែងមួយចំនួន )ដែលយើងទៅ។

ច. យើងគួរស្រលាញ់ព្រះ ........(**គ្រប់ពេល**/ពេលខ្លះ)

ឆ. យើងគួរតែស្រឡាញ់ទ្រង់គ្រប់ពេលវេលា។ យើងគួរតែផ្តល់ឲ្យព្រះអង្គនូវ ...............(**ដួងចិត្តទាំងអស់**/លុយទាំងអស់)របស់យើង។

៣. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងគួរតែ ស្រឡាញ់ទ្រង់គ្រប់ពេលវេលា។ យើងគួរតែផ្តល់ឲ្យព្រះអង្គនូវដួងចិត្តទាំងអស់របស់យើង ពីព្រោះទ្រង់ស្រលាញ់យើងហើយចង់ឲ្យយើងនូវអ្វី ដែលល្អដល់យើង។

## ៨. ខគម្ពីរចងចាំ

**ខគម្ពីរចងចាំ៖ ចោទិយកថា ៦៖៥** *" ត្រូវឲ្យឯងស្រឡាញ់ព្រះយេហូវ៉ា ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ពីកំឡាំងឯង។"*

## ៩. ហាត្ថកម្ម «អស់ពីដួងចិត្តខ្ញុំ»

សម្ភារៈដែលត្រូវការ៖ សូមបោះពុម្ពរូបបេះដូងនៅខាងក្រោម កូល័រ និងកន្ត្រៃ

១. សូមបោះពុម្ពក្រដាសរូបបេះដូងសម្រាប់កុមារគ្រប់ៗគ្នា

២. ឲ្យកុមារកាត់រូបបេះដូងចេញមកហើយតុបតែងវា

៣. បត់រូបបេះដូងមួយចំហៀងសងខាងចូលគ្នា ដើម្បីធ្វើជាគម្របបេះដូងពេញ។




៤. នៅចំកណ្តាលរូបបេះដូងសូមឲ្យកុមារសរសេរថា " ខ្ញុំស្រលាញ់ព្រះអស់ពីដួងចិត្តខ្ញុំ!"

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន )**
ប្រាជ្ញាព្រះគម្ពីរមិនគ្រាន់តែដឹងការពិតអំពីព្រះយេស៊ូវទេ-វាគឺជាការរស់នៅដោយមិត្តភាពជាមួយ និងការគោរពចំពោះព្រះគ្រីស្ទ។ ប្រាជ្ញាបង្កើតឱ្យមានការផ្លាស់ប្ដូរ មិនមែនគ្រាន់តែជាពត៌មានប៉ុណ្ណោះទេ។ សូមអាន **២ របាក្សត្រ ៧៖១៤**។ ជាយូរមកហើយមុនពេលដែលចិត្តរបស់សាឡូម៉ូនវង្វេង ហើយដោយសារសេចក្ដីល្បួងដាច់ឆ្ងាយពីព្រះ នោះព្រះបានដឹកនាំផ្លូវគាត់ និងរាស្ដ្ររបស់គាត់ដើម្បីស្ដារចំណងមិត្តភាពរបស់ពួកគេជាមួយនឹងព្រះ។ យើងអាចធ្វើតាមផ្លូវដែលព្រះបានបង្ហាញ ឲ្យត្រឡប់រកទៅព្រះវិញពេលយើងមិនស្ដាប់បង្គាប់របស់ទ្រង់។ សូមចំណាយពេលមួយនាទីដើម្បីឆ្លុះបញ្ចាំង ហើយពិចារណាពីតម្រូវការរបស់អ្នកដើម្បីសារភាពអំពើបាបចំពោះព្រះ។

